ទំនុកដំកើង៥១:១-១៩

# ជំពូក ៥១

***ធាតុចនា*** *បទព្រះបាទដាវីឌលន់តួបាប*

យើងឃើញចំណងជើងនៃគម្ពីរទំនុកដំកើងជំពូក៥១ ចារទុកថាជាទំនុករបស់ស្ដេចដាវីឌ លើកសម្រាប់មេភ្លេង នៅពេលដែលហោរាណាថាន់បានមកឯងទ្រង់ បន្ទាប់ពីទ្រង់ចូលទៅឯនាងបាតសេបា។ ដើម្បីអោយយល់ហេតុការណ៍ ដែលនាំអោយព្រះបាទដាវីឌកត់ត្រាសេចក្ដីមានចែងនៅក្នុងគម្ពីរទំនុកដំកើងជំពូក៥១ យើងត្រូវពិចារណារឿងកើតឡើងរវាងព្រះបាទដាវីឌ និងនាងបាតសេបា។ គម្ពីរ២សាំយូអែល១២:១-១៤ រៀបរាប់រឿងនោះ។ "ព្រះយេហូវ៉ាទ្រង់ចាត់ណាថាន់ ឲ្យទៅឯដាវីឌលោកក៏ទៅគាល់ទ្រង់ ទូលដូច្នេះថា នៅទីក្រុង១មានមនុស្ស២នាក់ ម្នាក់ជាអ្នកមាន ម្នាក់ក្រីក្រ អ្នកដែលមាននោះ មានចៀមហើយនឹងគោយ៉ាងសន្ធឹក តែអ្នកដែលក្រគ្មានអ្វីសោះ មានតែកូនចៀម១ ដែលបានទិញមកចិញ្ចឹមប៉ុណ្ណោះ កូនចៀមនោះក៏ចំរើនធំឡើងនៅជាមួយនឹងគាត់ ហើយនឹងកូនគាត់ វាតែងស៊ីអាហារ ហើយផឹកពីពែងរបស់គាត់ ក៏ដេកនៅនាដើមទ្រូងគាត់ដែរ គាត់ទុកវាដូចជាកូនស្រីរបស់ខ្លួន គ្រានោះ មានអ្នកដំណើរម្នាក់មកឯមនុស្សអ្នកមាននោះ តែអ្នកមានមិនព្រមយកសត្វណាមួយពីហ្វូងចៀមហ្វូង

គោរបស់ខ្លួន ដើម្បីនឹងចាត់ចែងរៀបចំទទួលអ្នកដំណើរ ដែលមកឯខ្លួននោះទេ គឺបានចាប់យកកូនចៀមរបស់អ្នកក្រីក្រនោះ ទៅចាត់ចែងទទួលអ្នកដែលមកនោះវិញ ដូច្នេះ ដាវីឌទ្រង់មានសេចក្តីខ្ញាល់ក្តៅឡើងចំពោះអ្នកនោះជាខ្លាំង ក៏មានបន្ទូលទៅណាថាន់ថា យើងស្បថដោយនូវព្រះយេហូវ៉ាដ៏មានព្រះជន្មរស់នៅថា មនុស្សណាដែលប្រព្រឹត្តដូច្នោះគួរស្លាប់ហើយ ត្រូវឱ្យវាសង១ជា៤ជំនួសចៀមនោះ ដោយព្រោះបានប្រព្រឹត្តឥតប្រណីដូច្នោះ។ នោះណាថាន់ទូលសបថា ឯមនុស្សនោះ គឺជាអង្គទ្រង់នេះហើយ ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូលដូច្នេះថា អញបានចាក់ប្រេងតាំងឯងឡើងជាស្តេចនៃសាសន៍អ៊ីស្រាអែល ក៏បានជួយឯងឱ្យរួចពីកណ្តាប់ដៃរបស់សូល ហើយបានប្រគល់ដំណាក់ នឹងប្រពន្ធទាំងប៉ុន្មានរបស់ចៅហ្វាយឯង មកឱ្យឯងឱបនៅនាទ្រូង ព្រមទាំងឱ្យពូជពង្សអ៊ីស្រាអែល នឹងយូដា មកក្នុងអំណាចឯងដែរ បើនៅមិនល្មមគ្រាន់ នោះអញនឹងបន្ថែមយ៉ាងនេះមួយៗឱ្យថែមទៀត ហេតុអ្វីបានជាឯងមើលងាយ ផ្តោះព្រះបន្ទូលនៃព្រះយេហូវ៉ា ដោយប្រព្រឹត្តការអាក្រក់ នៅព្រះនេត្រទ្រង់ដូច្នេះ ឯងបានសំឡាប់អ៊ូរី ជាសាសន៍ហេតដោយដាវ ក៏ក្បត់យកប្រពន្ធគាត់មកធ្វើជាប្រពន្ធឯង ហើយសំឡាប់គាត់ដោយដាវរបស់ពួកកូនចៅអាំម៉ូន ដូច្នេះ ដាវមិនដែលឃ្លាតពីគ្រួឯងឡើយ ដ្បិតឯងបានមើលងាយដល់អញ ហើយបានយកប្រពន្ធរបស់អ៊ូរីជាសាសន៍ហេត មកធ្វើជាប្រពន្ធរបស់ឯង ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ចាំមើល អញនឹងបណ្តាលឱ្យមានការអាក្រក់កើតឡើង ពីក្នុងគ្រួឯង ឱ្យទាស់នឹងឯង ក៏នឹងយកពួកប្រពន្ធទាំងប៉ុន្មានរបស់ឯង ប្រគល់ឱ្យដល់អ្នកជំនិតឯងនៅមុខឯងផង អ្នក

នោះនឹងរួមដំណេកនឹងប្រពន្ធឯងទាំងនោះ នៅទីពន្លឺថ្ងៃ ដ្បិតឯងបានធ្វើការនោះដោយសំងាត់ តែអញនឹងធ្វើការនេះនៅទីពន្លឺវិញ ឱ្យពួកអ៊ីស្រាអែលទាំងអស់គ្នាបានឃើញ រួចដាវីឌមានបន្ទូលទៅណាថាន់ថា យើងបានធ្វើបាបនឹងព្រះយេហូវ៉ាហើយ ណាថាន់ក៏ទូលតបថា ព្រះយេហូវ៉ាក៏បានប្រោសលើកទោសទ្រង់ចោលដែរ ទ្រង់មិនត្រូវសុគតទេ ប៉ុន្តែ ដោយប្រព្រឹត្តអំពើយ៉ាងនេះ ទ្រង់បានឱ្យពួកខ្មាំងសត្រូវនៃព្រះយេហូវ៉ា មានឱកាសនឹងត្មះតិះដៀលជាខ្លាំង បានជាបុត្រដែលត្រូវប្រសូតមកនោះ នឹងសុគតទៅជាពិតប្រាកដ រួចណាថាន់ក៏វិលទៅផ្ទះលោកវិញទៅ"។

ព្រះបាទដាវីឌជាក្សត្រមួយអង្គដែលព្រះជាម្ចាស់រាប់ថា ជាអ្នកដែលធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះអង្គគ្រប់ជំពូក។ ការផ្ដល់ងារខ្ពង់ខ្ពស់បែបនេះមិនមែនមានន័យថា ព្រះបាទដាវីឌជាមនុស្សមិនបានប្រព្រឹត្តអំពើបាបណាមួយនោះទេ។ តាមពិតព្រះបាទដាវីឌបានប្រព្រឹត្តអំពើបាបធំជាងគេបង្អស់ចំនួនពីរដង។ ម្ដង ស្ដេចអង្គនេះ បានបំពានលើក្រឹត្យវិន័យទីប្រាំពីរដែលសម្ដែងថា "កុំឱ្យផិតក្បត់ឱ្យសោះ"។ ព្រះបាទដាវីឌបានប្រព្រឹត្តអំពើផិតជាមួយនឹងនាងបាតសេបា។ ម្ដងទៀត ស្ដេចអង្គនេះ បានបំពានក្រឹត្យវិន័យទីប្រាំមួយគឺ "កុំសម្លាប់មនុស្សឱ្យសោះ"។ ស្ដេចអង្គនេះ បានសម្លាប់មេទ័ពអ៊ូរីដែលត្រូវជាប្ដីរបស់នាងបាតសេបា។ មេទ័ពអ៊ូរី មានភក្ដីភាពចំពោះព្រះបាទដាវីឌណាស់។ លោកចំណាយជីវិត ចំណាយធនធានរបស់លោកសម្រាប់បម្រើដល់ស្ដេចដាវីឌតែមួយអង្គគង់។ ប៉ុន្តែ ព្រះបាទដាវីឌមិនបានស្រឡាញ់ដល់ជាវបម្រើរបស់លោកទេ។ លោកបានបង្គាប់អោយគេបញ្ជូនមេទ័ពរូបនេះ អោយទៅឱ្យស្លាប់នៅសមរភូមិ

មុខ។ នៅចំពោះព្រះនេត្ររបស់ព្រះជាម្ចាស់ កិរិយាដែលព្រះបាទដាវីឌបានប្រព្រឹត្ត ជាអំពើអាក្រក់យ៉ាងខ្លាំងក្រៃលែងឥតឧបមា។

ចុះហេតុអ្វីបានជាព្រះជាម្ចាស់រាប់ព្រះបាទដាវីឌថា ជាបុគ្គលដែលធ្វើតាមព្រះអង្គគ្រប់ជំពូក? ដោយសារឋានៈបែបនេះ តើព្រះបាទដាវីឌបានរួចខ្លួនពីអំពើបាប ដែលលោកបានប្រព្រឹត្តដែរឬទេ? ទោះបីព្រះបាទដាវីឌមានឋានៈជាបាវបម្រើរបស់ព្រះជាម្ចាស់ក៏ដោយ ព្រះបាទដាវីឌចាំបាច់ត្រូវទទួលផលនៃអំពើបាប ដែលលោកបានប្រព្រឹត្ត។ នៅចន្លោះគ្រាដែលស្តេចអង្គនេះបានប្រព្រឹត្តអំពើបាបទាំងពីរយ៉ាងខាងលើ នឹងរយៈពេលដែលហោរាណាថាន់បានមកជួបលោក ស្តេចអង្គនេះមានការតានតឹងក្នុងចិត្តឥតឧបមា។ ក្នុងគម្ពីរទំនុកដំកើងជំពូក៣២ ព្រះបាទដាវីឌមានបន្ទូលថា "កាលទូលបង្គំបានស្ងៀមនៅ នោះឆ្អឹងទូលបង្គំបានខ្សោះទៅ ដោយសារដំងូរដែលទូលបង្គំថ្ងូរជាដរាបរាល់ថ្ងៃ ដ្បិតព្រះហស្តនៃទ្រង់បានសង្កត់លើទូលបង្គំជាធ្ងន់ទាំងយប់ទាំងថ្ងៃ ធាតុទឹករបស់ទូលបង្គំបានត្រឡប់ទៅជារីងហួតដូចនៅរដូវក្តៅ-បង្អង់" (ទំនុកដំកើង៣២:៣-៤)។ ខខាងលើបញ្ជាក់ពីវិប្បដិសារី ពីការលំបាកចិត្តដែលព្រះបាទដាវីឌត្រូវទទួលបន្ទាប់ពីធ្វើបាបទាស់នឹងខ្លួនលោក ទាស់នឹងនាងបាតសេបា និងទាស់នឹងព្រះ។

ព្រះជាម្ចាស់បានបញ្ជូនហោរាណាថាន់ អោយមកដាស់តឿនដល់ស្តេចដាវីឌថា លោកបានប្រព្រឹត្តអំពើបាបទាំងនោះ។ នៅក្នុងព្រះគម្ពីរទាំងមូល ហោរាណាថាន់រាប់ថា ជាហោរាមានទឹកចិត្តក្លាហានជាទីបំផុត។ នៅក្នុងគម្ពីរ២សាំយូអែល១២:៧ ពេលដែលព្រះបាទដាវីឌ ខឹងសម្បាជាមួយនឹងមនុស្សដែលលោកវិនិច្ឆ័យប្រព្រឹត្តអាក្រក់

ហោរាណាថាន់លើកដៃចង្អុលចំមុខព្រះបាទដាវីឌហើយពោលថា “មនុស្សអាក្រក់នោះ គឺ ព្រះអង្គឯងនេះហើយ!” ប្រឈមមុខនឹងស្ថានការណ៍អាក្រក់បែបនេះ ស្តេចដាវីឌជាស្តេចគ្រប់គ្រងផែនដីអាចធ្វើការបីយ៉ាង។ មួយ ព្រះបាទដាវីឌអាចបដិសេធថា ការចោទប្រកាន់នេះគ្មានភ័ស្តុតាងត្រឹមត្រូវ។ មួយទៀត ស្តេចអង្គនេះអាចយកដំបងរាជ្យចង្អុលចំហោរាណាថាន់ នោះពេជ្ឈឃាតរបស់ស្តេចអង្គនេះ ឡើងមកចាប់លោកណាថាន់ទៅញាត់ក្នុងទីឃុំឃាំង។ ដើម្បីធ្វើតាមនិតិរដ្ឋ ព្រះបាទដាវីឌបង្គាប់អោយគេវាយបង្ខំហោរាណាថាន់ សារភាពនៅចំពោះមុខតុលាការថា លោកបានចោទប្រកាន់ដល់ស្តេចដោយគ្មានភ័ស្តុតាង។ ធ្វើបែបនេះ ព្រះបាទដាវីឌស៊ីហើយជូតមាត់ស្អាតថៃស។

ឯករណីទីបី ព្រះបាទដាវីឌព្រមសារភាពថា លោកបានប្រព្រឹត្តអំពើបាបនោះមែន។ ព្រះបាទជ្រើសរើសជម្រើសទីបី។ ស្តេចអង្គនេះលន់តួអំពើបាបរបស់ទ្រង់។ ធម្មតាទោះស្តេចប្រទេសណាក៏ដោយ សុទ្ធតែអង្គុយលើច្បាប់ទាំងអស់។ ក្នុងករណីព្រះបាទដាវីឌ ទ្រង់ជ្រើសរើសស្ថិតនៅក្រោមច្បាប់របស់នគរ ក៏ដូចជាច្បាប់របស់ព្រះជាម្ចាស់ដែរ។ ទ្រង់សារភាពនូវអំពើបាបដែលទ្រង់បានប្រព្រឹត្ត។

ព្រះជាម្ចាស់បង្គាប់អោយហោរាណាថាន់ ទូលថ្វាយដល់ព្រះបាទដាវីឌនូវកម្រិតទោសដែលស្តេចដាវីឌត្រូវទទួល។ សេចក្តីពិស្តារមានបរិយាយនៅក្នុងអត្ថបទខាងលើ គឺ២សាំយូអែល១២:១០-១៤។ ខាងលើជាសាវតារដែលនាំអោយព្រះបាទដាវីឌកត់ត្រាទុកសេចក្តីដែលយើងឃើញមានសម្តែងនៅក្នុងគម្ពីរទំនុកដំកើងជំពូក៥១។

ចាវបម្រើគ្រប់រូបរបស់ព្រះជាម្ចាស់ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញកន្លងមក

សុទ្ធតែបានសរសេរការលន់តួបាបរបស់លោកនៅចំពោះព្រះជាម្ចាស់។ ប៉ុន្តែ បើប្រៀបធៀបការលន់តួបាបទាំងអម្បាលមាណ ទៅនឹងការលន់តួបាបដែលព្រះបាទដាវីឌបានកត់ត្រាទុកក្នុងគម្ពីរទំនុកដំកើងជំពូក៥១ ការលន់តួបាបនេះមានខ្លឹមសារយ៉ាងជ្រាលជ្រៅ ដែលមនុស្សលោកពិបាកនឹងរៀបរាប់អោយបានចំចំណុចដូចព្រះបាទដាវីឌបានសរសេរទុក។

ជំពូក៥១ ចែកជាបីផ្នែកធំៗគឺ ផ្នែកទីមួយ ពីខ១-៣ សម្រែកនៃការសារភាពអំពើបាប។ ទីពីរ ពីខ៤-៨ សម្រែកនៃការលន់តួអំពើបាប និងទីបី ពីខ៩-១៩ សម្រែកទូលសូមការលាងសម្អាត និងការរួមសម្ពន្ធវង្សបរិសុទ្ធឡើងវិញជាមួយនឹងព្រះជាម្ចាស់។

## សម្រែកនៃការសារភាពអំពើបាប

ព្រះបាទដាវីឌបានលន់តួអំពើបាបរបស់លោកថា

**[១]ឱព្រះអង្គអើយ សូមអាណិតមេត្តាដល់ទូលបង្គំ តាមសេចក្ដី
សប្បុរសរបស់ទ្រង់ ហើយសូមលុបសេចក្ដីរំលងរបស់ទូលបង្គំ
ចេញ ដោយសេចក្ដីមេត្តាករុណាដ៏បរិបូររបស់ទ្រង់ [២]សូមលាង
ទូលបង្គំឱ្យយ៉ាងស្អាត ពីអំពើទុច្ចរិតរបស់ទូលបង្គំ សូមសំអាត
អំពើបាបរបស់ទូលបង្គំផង [៣]ដ្បិតទូលបង្គំទទួលស្គាល់អំពើរំលង**

**របស់ទូលបង្គំហើយ ឯអំពើបាបរបស់ទូលបង្គំ នោះក៏នៅចំពោះមុខទូលបង្គំជានិច្ច (ទំនុកដំកើង៥១:១-៣)។**

រូបភាពនៃអំពើបាបមានទ្រង់ទ្រាយស្មុគស្មាញខ្លាំងណាស់។ ឥឡូវ សូមលោកអ្នកយកបន្ទាត់ត្រង់មួយមកកាន់។ ចូរលើកបន្ទាត់នោះអោយត្រង់ឡើងលើ។ តើលោកអ្នកឃើញបន្ទាត់ត្រង់មានទ្រង់ទ្រាយប៉ុន្មានយ៉ាង? បន្ទាត់ត្រង់មានទ្រង់ទ្រាយតែម្យ៉ាងគត់។ ឥឡូវ សូមលោកអ្នករកមែកឈើវៀចមួយមកកាន់។ តើមែកឈើវៀចមានទ្រង់ទ្រាយប៉ុន្មានសណ្ឋាន? មែកឈើវៀចមានសណ្ឋានរាប់លានបែប។ កិរិយាវៀចវេរជាផ្នែកមួយនៃអំពើបាប។

ព្រះបាទដាវីឌបានគូររូបភាពអំពើបាបក្នុងកិរិយាបីយ៉ាង។ មួយ ស្តេចអង្គនេះបានហៅអំពើបាបថា ជាអំពើរំលង។ ពាក្យថា អំពើរំលងមានន័យថា កិរិយាដែលប្រព្រឹត្តហួសព្រំដែន ដែលព្រះជាម្ចាស់កំណត់មកសម្រាប់មនុស្សជាតិ។ ព្រះអង្គប្រទានអោយមនុស្សលោកមានសិទ្ធិធ្វើការខ្លះបាន ឯការខ្លះទៀតមិនអាចធ្វើបាន។ ព្រំដែនទាំងនោះហើយ ដែលព្រះជាម្ចាស់កំណត់មកសម្រាប់មនុស្សលោក។ ព្រះជាម្ចាស់បង្កើតរូបមន្តគីមី រូបមន្តសីលធម៌ និងរូបមន្តខាងព្រលឹងវិញ្ញាណ។ ជនណាក៏ដោយអោយតែហ៊ានប្រព្រឹត្តខុសច្បាប់កំណត់ក្នុងរូបមន្តទាំងនោះ ជននោះពិតជាត្រូវទទួលលទ្ធផលអាក្រក់ណាមួយជាប្រាកដ។ ការប្រព្រឹត្តហួសព្រំដែន ដែលព្រះជាម្ចាស់កំណត់សម្រាប់មនុស្សលោកហៅថា កិរិយារំលង។ កិរិយារំលងជាសាខាមួយនៃអំពើបាប។

មួយទៀត ព្រះបាទដាវីឌបានហៅអំពើបាបថា ជាអំពើទុច្ចរិត។ ពាក្យថា ទុច្ចរិត មានន័យថា ឥតរកអ្វីឃើញថាល្អបន្តិចបន្តួចសោះ។ ព្រះបន្ទូលថែងថា កិរិយារបស់មនុស្សលោកសុទ្ធតែទុច្ចរិត។ អំពើទុច្ចរិតជាសាខាមួយនៃអំពើបាបដែរ។

សាខាទីបីនៃអំពើបាបឃើញថែងក្នុងជំពូក៥១:៤។ ព្រះបាទដាវីឌហៅសាខានៃអំពើបាបមួយនេះថា ជាអំពើបាបចំកូតែម្តង។ អំពើបាបគឺអំពើប្រព្រឹត្តមិនចំចំណុចដៅ។ ព្រះជាម្ចាស់បង្កើតមនុស្សលោកមកមានចំណុចដៅរូមមួយសម្រាប់ខ្លួន។ មនុស្សលោកត្រូវប្រព្រឹត្តអោយដូចកិរិយាដែលព្រះជាម្ចាស់បានបង្គាប់គេអោយធ្វើ។ ប៉ុន្តែមនុស្សគ្រប់រូបមិនអាចប្រព្រឹត្តបានតាមចំណុចដែលព្រះដៅសម្រាប់ខ្លួន។ ដូច្នេះហើយបានជាយើងមានឋានៈជាមនុស្សមានបាបនៅចំពោះព្រះជាម្ចាស់។ គម្ពីររ៉ូម៣:២៣ សម្តែងថា "...ពីព្រោះគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ"។

ព្រះបាទដាវីឌទទួលស្គាល់ថា លោកបានប្រព្រឹត្តអំពើបាប។ លោកបានប្រព្រឹត្តមិនចំចំណុចដែលព្រះជាម្ចាស់ដាក់អោយលោកធ្វើ។ ដោយសារមូលហេតុនោះហើយបានជាលោកមានសេចក្តីតានតឹងនៅក្នុងចិត្តយ៉ាងខ្លាំង។ លោកស្អប់អំពើបាប លោកស្អប់អំពើដែលលោកបានប្រព្រឹត្ត។ នៅក្នុងមនសិការរបស់លោកមើលឃើញមានអំពើស្មោកគ្រោកយ៉ាងខ្លាំងកំពុងគ្របសង្កត់មកលើព្រលឹងលោក។ អំពើបាបទាំងពីរយ៉ាងនោះ មានទម្ងន់ជាងភ្នំព្រះសុមេរុ សង្កត់មកលើរូបលោករៀងរាល់ដង្ហើមចេញចូល។ ក្នុងវិញ្ញាណរបស់លោក មានសេចក្តីតានតឹង ចេះតែចោទប្រកាន់ខ្លួនឯងថា លោកមិនគួរប្រព្រឹត្តអំពើស្មោកគ្រោកជាទីបំផុតនេះទេ។ វិប្បដិសារីកំពុងជេរស្តីលោក ចង្អុលមុខ

លោកប្រាប់ថា លោកបានប្រព្រឹត្តខុស។

មនុស្សយើងគ្រប់រូប ស្ថិតនៅក្រោមការគ្រប់គ្រងនៃមនសិការ។ តួនាទីរបស់មនសិការមិនមែនប្រាប់យើងអោយដឹងថា កិរិយាណាមួយជាកិរិយាខុស ឬជាកិរិយាត្រូវទេ។ តួនាទីរបស់មនសិការប្រាប់យើងថា យើងធ្វើខុសឬត្រូវ។ ខ្ញុំសូមជូនឧទាហរណ៍មួយ ក្នុងករណីសាវ័កប៉ុលមានប្រសាសន៍ពីការទទួលទានសាច់។ ករណីនេះមានចែងក្នុងគម្ពីរ១កូរិនថូស១០:២៥-២៩។ លោកបញ្ជាក់ថា ការទទួលទានសាច់ដែលបានថ្វាយទៅរូបព្រះរូចហើយ ឥតទាក់ទងអ្វីនឹងសេចក្ដីសង្គ្រោះរបស់យើងទេ។ ប៉ុន្តែ បើបញ្ញាចិត្ត គឺមនសិការចោទប្រកាន់ សូមកុំអោយទទួលទាន។ មនសិការប្រាប់យើងថា យើងធ្វើខុស ឬធ្វើត្រូវ។ ជនណាដែលធ្វើទាស់ទទឹងនឹងមនសិការរបស់ខ្លួន ជននោះពិតជាត្រូវទទួលគ្រោះកាចណាមួយនៅក្នុងជីវិតជាមិនខាន។

ព្រះបាទដាវីឌស្ដាប់តាមមនសិការរបស់លោក ពីព្រោះមនសិការរបស់លោកបង្គាប់ដល់លោកថា លោកបានប្រព្រឹត្តអំពើបាប។ ដោយសារមនសិការរបស់លោកបង្គាប់អោយលោកទទួលស្គាល់ថា អំពើដែលលោកបានប្រព្រឹត្តជាអំពើបាប លោកមិនចាំរកលេសណាមួយមកការពារដល់អំពើបាបដែលលោកបានប្រព្រឹត្តទេ។ ផ្ទុយទៅវិញលោកសារភាពថា

**ដ្បិតទូលបង្គំទទួលស្គាល់អំពើរំលងរបស់ទូលបង្គំហើយ ឯអំពើ**

**បាបរបស់ទូលបង្គំ នោះក៏នៅចំពោះមុខទូលបង្គំជានិច្ច (ទំនុកដំកើង៥១:៣)។**

ព្រះបាទដាវីឌសារភាពថា លោកបានប្រព្រឹត្តអំពើបាបទាំងពីរយ៉ាងមែន។

## សម្រេចនៃការលន់តួអំពើបាប

ផ្នែកទីពីរបរិយាយពីសម្រេចនៃការលន់តួអំពើបាប និងការទទួលស្គាល់នូវសេចក្ដីមេត្តាករុណារបស់ព្រះជាម្ចាស់ចំពោះមនុស្សមានបាប។

**ទូលបង្គំបានធ្វើបាបនឹងទ្រង់ហើយ គឺនឹងទ្រង់តែ១ព្រះអង្គ ព្រមទាំងប្រព្រឹត្តសេចក្ដីដែលអាក្រក់នៅព្រះនេត្រទ្រង់ផង ទូលបង្គំទទួលស្គាល់អំពើទាំងនោះ ដើម្បីឱ្យទ្រង់បានរាប់ជាសុចរិតក្នុងកាលដែលទ្រង់មានបន្ទូល ហើយឱ្យបានឥតសៅហ្មងក្នុងកាលដែលទ្រង់ជំនុំជំរះ(ទំនុកដំកើង៥១:៤)។**

ព្រះបាទដាវីឌបានសារភាពថា លោកបានធ្វើបាបទាស់នឹងព្រះជាម្ចាស់។ តើកិរិយាដែលលោកប្រព្រឹត្តខុសជាមួយនឹងនាងបាតសេបា មិនមែនជាទោសដែលលោក

ធ្វើទាស់ជាមួយនឹងនាងទេឬ? មែនហើយ! អំពើបាបដែលលោកបានប្រព្រឹត្ត ទាស់នឹងនាងបាតសេបា ទាស់នឹងលោកអ៊ូរី ទាស់នឹងក្រុមគ្រួសាររបស់លោក ទាស់នឹងសង្គមមនុស្សដែលលោកគ្រប់គ្រង។ ស្តេចដាវីឌជាក្សត្រគ្រប់គ្រងនគរទាំងមូល។ ការប្រព្រឹត្តអំពើបាបក្នុងនាមជាអ្នកគ្រប់គ្រង ប្រព្រឹត្តអំពើបាបទាស់នឹងប្រជាពលរដ្ឋ។ អំពើបាបទាំងអម្បាលមាណនោះ កើតឡើងដោយសារព្រះបាទដាវីឌបានធ្វើបាបទាស់នឹងព្រះជាម្ចាស់។ ព្រះបាទដាវីឌប្រព្រឹត្តអំពើបាបទាស់នឹងព្រះជាម្ចាស់ ពីព្រោះមកទល់ពេលសព្វថ្ងៃ នាងបាតសេបាបានស្លាប់បាត់បង់ជីវិតទៅហើយ។ ក្រុមគ្រួសាររបស់ព្រះបាទដាវីឌក៏ត្រូវរលំរលាយបាត់ពីផែនដីនេះទៅ។ ឯរាជ្យរបស់ព្រះបាទដាវីឌគ្រប់គ្រងនគរអីស្រាអែល ក៏ត្រូវបាត់បង់អស់ទៅហើយដែរ។ តើអ្វីដែលនៅសល់មកទល់សព្វថ្ងៃនេះ? គឺអំពើបាបរបស់ព្រះបាទដាវីឌ ដែលប្រព្រឹត្តទាស់នឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់។ អំពើបាបរបស់ដាវីឌ នៅមាននឹងភ្នែកយើង ក្នុងម៉ោងនេះ ពេលនេះ និងវិនាទីនេះ។ ដូច្នេះហើយ បានជាព្រះបាទដាវីឌមានប្រសាសន៍ថា ទ្រង់បានប្រព្រឹត្តអំពើបាបទាស់នឹងព្រះជាម្ចាស់។

ព្រះបាទដាវីឌត្រូវទទួលទោស ជាលទ្ធផលនៃអំពើបាបដែលលោកបានប្រព្រឹត្ត។ ឯលទ្ធផលដែលព្រះបាទដាវីឌត្រូវទទួលមានសម្តែងនៅក្នុងគម្ពីរ២សាំយូអែល ១២:១៣-១៤។ ឯលទ្ធផល មួយ កូនប្រុសដែលលោកបង្កើតជាមួយនឹងនាងបាតសេបា ដោយផិតត្រូវស្លាប់។ មួយទៀត គម្ពីរ២សាំយូអែលជំពូក១៨ ចែងថា បុត្រារបស់ព្រះបាទដាវីឌ នាមអាប់សាឡុំម ងើបឡើងបះបោរដណ្តើមរាជបល្ល័ង្កពីព្រះបាទដាវីឌ។

ព្រះបាទដាវីឌត្រូវទទួលលទ្ធផលនៃអំពើបាបរបស់លោក។

ម្យ៉ាងវិញទៀត សូមកត់ចំណាំថា ព្រះបាទដាវីឌទទួលស្គាល់នូវដើមកំណើតនៃអំពើបាបនៅក្នុងចិត្តរបស់លោក។ លោកមានប្រសាសន៍ថា:

**មើល ទូលបង្គំបានកើតមកក្នុងសេចក្តីទុច្ចរិត ហើយម្តាយទូលបង្គំបានមានទំងន់ បង្កើតទូលបង្គំនៅក្នុងអំពើបាបដែរ (ទំនុកដំកើង ៥១:៥)។**

ព្រះបាទដាវីឌក៏ដូចជាមនុស្សទូទៅដែរ ទទួលស្គាល់ថាយើងកើតមកក្នុងពិភពលោកដែលមានបាប។ សាវ័កប៉ុលទទួលស្គាល់ដែរថា "ឱបងប្អូនអើយ បើបានទាន់ឃើញមនុស្សណាធ្វើខុសអ្វី នោះអ្នករាល់គ្នាដែលដើរដោយព្រះវិញ្ញាណ ចូរដំរង់អ្នកនោះដោយចិត្តសុភាព ព្រមទាំងប្រយ័តខ្លួនឯងផង ក្រែងត្រូវសេចក្តីល្បួងដែរ" (កាឡាទី៦:១)។ មនុស្សទូទៅនៅលើសកលលោកយើងនេះ ទោះអ្នកចេះ អ្នកល្ងង់ ស្តេច មន្ត្រី សង្ឃ ឬប្រជារាស្ត្រសុទ្ធតែទទួលស្គាល់ថា កិរិយាប្រព្រឹត្តមិនបានគ្រប់លក្ខណ៍ដប់ទាំងដប់ទេ។ ព្រះបាទសាឡូម៉ូនសរសេរក្នុងគម្ពីរសាស្តា៧:២០ថា "ពិតប្រាកដជាគ្មានមនុស្សសុចរិតណានៅផែនដី ដែលប្រព្រឹត្តសុទ្ធតែល្អឥតធ្វើបាបឡើយនោះទេ"។ គម្ពីរសុភាសិត៣០:១២ សម្តែងដែរថា "មានសម័យ១ ដែលមនុស្សមើលខ្លួនឯង ស្មានថាបរិសុទ្ធ ប៉ុន្តែគេមិនទាន់បានលាងជំរះសេចក្តីស្មោកគ្រោករបស់គេ

ចេញនៅឡើយទេ"។ សាវ័កប៉ុលបញ្ជាក់បន្ថែមក្នុងគម្ពីររ៉ូម៧:១៨ថា "ដ្បិតខ្ញុំដឹងថា នៅក្នុងខ្លួនខ្ញុំ គឺក្នុងសាច់ឈាមខ្ញុំ គ្មានអ្វីល្អទេ ព្រោះខ្ញុំមានចិត្តចង់ធ្វើល្អជានិច្ច ប៉ុន្តែរកធ្វើមិនកើតសោះ"។ ព្រះបាទដាវីឌទទួលស្គាល់នូវដើមកំណើតនៃអំពើបាប។ ទ្រង់សារភាពថា "...ទូលបង្គំបានកើតមកក្នុងសេចក្តីទុច្ចរិត ហើយម្តាយទូលបង្គំបានមានទំងន់ បង្កើតទូលបង្គំនៅក្នុងអំពើបាប..."

ព្រះបាទដាវីឌលន់តួអំពើបាបរបស់លោកថា

> **មើល ទ្រង់ប្រាថ្នាចង់បានសេចក្តីពិតនៅចំណែកខាងក្នុង ហើយគឺនៅទីលាក់កំបាំងខាងក្នុង ដែលទ្រង់នឹងធ្វើ ឲ្យទូលបង្គំស្គាល់ប្រាជ្ញាដែរ (ទំនុកដំកើង៥១:៦)។**

ព្រះជាម្ចាស់ទតមើលឃើញកិរិយាប្រព្រឹត្តដែលមាននៅក្នុងចិត្តមនុស្ស។ ព្រះអង្គមិនយកព្រះហឫទ័យទុកដាក់តែនឹងសំបកក្រៅប៉ុណ្ណោះទេ។ ទោះបីលោកអ្នកជ្រមុជទឹកជាច្រើនដងហើយក៏ដោយ លោកអ្នកប្រហែលជាគ្រាន់តែមនុស្សមានបាបជ្រមុជទឹកលាងខ្លួនតែប៉ុណ្ណោះ មិនទាន់បានលាងចិត្តនៅឡើយ។ លោកអ្នកជាសមាជិករបស់ក្រុមជំនុំ តែលោកអ្នកប្រហែលជាសមាជិកក្រុមជំនុំ ដែលមិនទាន់បានទទួលសេចក្តីសង្គ្រោះ។ ព្រះជាម្ចាស់សព្វព្រះហឫទ័យ អោយយើងមានការផ្លាស់ប្រែនៅក្នុងចិត្តរបស់

យើង ដោយដើរតាមសេចក្តីពិតដែលព្រះអម្ចាស់បង្គាប់ដល់យើង ក្នុងព្រះបន្ទូលរបស់ទ្រង់។

> **សូមជំរះទូលបង្គំដោយមែកហ៊ីសុប នោះទូលបង្គំនឹងបានជ្រះស្អាត សូមដុសលាងទូលបង្គំ នោះនឹងបានសជាងហិមៈ (ទំនុកដំកើង៥១:៧)។**

ទាក់ទងនឹងសេចក្តីពិតដែលសម្តែងក្នុងខខាងលើ ខ្ញុំចង់អោយលោកអ្នកបងប្អូន តាមដានអោយបានស្អិតជាទីបំផុតពីគោលទិ្ធមួយនេះ។ ព្រះបាទដាវីឌទទួលសេចក្តីអត់ទោសបាបពីព្រះជាម្ចាស់ មិនមែនដោយសារស្តេចអង្គនេះលន់តួទេ។ សេចក្តីអត់ទោសមានស្រាប់មកពីព្រះជាម្ចាស់។ ព្រះអង្គទ្រង់ជាព្រះ ផ្តួចផ្តើមគំនិតនៃការអត់ទោសបាបដល់មនុស្សលោកណា ដែលលន់តួអំពើបាបរបស់ខ្លួន។

ក្នុងករណីព្រះបាទដាវីឌ ព្រះជាម្ចាស់បើកសម្តែងជាមុន អោយព្រះបាទដាវីឌដឹងថា មានផ្លូវដើម្បីទទួលបាននូវសេចក្តីអត់ទោសបាបពីទ្រង់។ ព្រះអង្គបានបើកសម្តែងដល់សាសន៍អ៊ីស្រាអែលរួចមកហើយថា "ទ្រង់យាងកាត់នៅមុខលោកទាំងប្រកាសថា យេហូវ៉ា គឺយេហូវ៉ាដ៏ជាព្រះទ្រង់មានព្រះហឫទ័យមេត្តាករុណា ហើយទន់សន្តោស ទ្រង់យឺតនឹងខ្ញាល់ ហើយមានសេចក្តីសប្បុរស នឹងសេចក្តីទៀងត្រង់ជាបរិបូរ ទ្រង់មានសេចក្តីមេត្តាករុណាដល់មនុស្សទាំងពាន់ ក៏អត់ទោសចំពោះសេចក្តីទុច្ចរិត

សេចក្ដីរំលង នឹងអំពើបាប ប៉ុន្ដែ ទ្រង់មិនរាប់មនុស្សមានទោសទុកជាឥតទោសឡើយ ទ្រង់ធ្វើទោសចំពោះសេចក្ដីទុច្ចរិតរបស់ឪពុក ទៅដល់កូនចៅដល់៣ហើយ៤ដំណផង" (និក្ខមនំ៣៤:៦-៧)។ អំពើបាបមានប្រសិទ្ធភាពដល់អ្នកប្រព្រឹត្ត បី ឬបួនដំណនៅខាងមុខ។ ប៉ុន្ដែ ព្រះជាម្ចាស់អាចអត់ទោសបាបដល់ជនណា ដែលព្រមលន់តួអំពើបាបរបស់ខ្លួន។ តើព្រះអង្គធ្វើដូចម្ដេច ដើម្បីអត់ទោសដល់អំពើបាបរបស់ជនដែលបានលន់តួ? ខខាងលើសម្ដែងថា "សូមជំរះទូលបង្គំដោយមែកហីសុប នោះទូលបង្គំនឹងបានជ្រះស្អាត"។ ព្រះជាម្ចាស់បំពេញតួនាទីជាអ្នកលាងជម្រះអំពើបាប ដល់អស់អ្នកណាដែលបានលន់តួអំពើបាបរបស់ខ្លួន។ ការលន់តួមិនអាចលាងអំពើបាបជ្រះទេ។ បើព្រះជាម្ចាស់គ្មានផែនការដើម្បីលាងបាបជនដែលធ្វើការលន់តួ នោះការលន់តួបាបឥតមានប្រយោជន៍អ្វីទាល់តែសោះ។ ព្រះអង្គជាអ្នកលាងជម្រះអំពើបាបរបស់ជនដែលបានលន់តួអំពើបាប់របស់ខ្លួននៅចំពោះព្រះអង្គ។ ព្រះអង្គប្រើមែកហីសុប ដើម្បីលាងសម្អាតអំពើបាប។ តើមែកហីសុបគឺជាអ្វី?

ហីសុប ជាតិណជាតិម្យ៉ាងដែលដុះនៅចន្លោះថ្មប្រេះ ពិសេសនៅទីមានធាតុសើមជានិច្ច។ ព្រះអង្គអោយប្រើមែកហីសុបក្នុងពិធីបីយ៉ាង។ ម្យ៉ាងនៅពេលបុណ្យរំលង គេត្រូវយកមែកហីសុបជ្រលក់នឹងឈាម ហើយលាបនៅលើក្របទ្វារ។ ម្យ៉ាងទៀត ពេលដែលព្រះជាម្ចាស់បង្គាប់អោយធ្វើយញ្ញបូជា បន្ទាប់ពីជាស្អាតរោគឃ្លង់ហើយ ព្រះអង្គអោយយកមែកហីសុបជ្រលក់ឈាមរួចហើយ ប្រោះលើសត្វមុននឹងលែងអោយវាហើរចេញទៅ។ ដំណើរនេះសម្ដែងពីសេចក្ដីសុគត និងការរស់ឡើងវិញនៃព្រះ

អម្ចាស់យេស៊ូវគ្រីស្ទ។ ម្យ៉ាងមួយទៀត រឿងនេះទាក់ទងនឹងពេលដែលសាសន៍អ៊ីស្រាអែលដើរកាត់ទីរហោស្ថាន។ ពេលនោះ បើមានមនុស្សណាធ្វើបាប គេត្រូវយកមែកហ៊ីសុបជ្រលក់ទឹក រួចហើយប្រោសនៅលើមនុស្សនោះ។ ពិធីនោះជាយញ្ញបូជា ធ្វើឡើងដើម្បីទទួលនូវការអត់ទោសបាប។

តើមែកហ៊ីសុបជាអ្វី? យើងត្រូវយកឈើឆ្កាងរបស់ព្រះអម្ចាស់យេស៊ូវមកពិចារណា ទើបយល់ពីមែកហ៊ីសុប។ គម្ពីរម៉ាថាយ២៧:៤៦ សម្តែងថា "ប្រហែលជាម៉ោង៣ នោះព្រះយេស៊ូវទ្រង់បន្លឺឡើងជាសំឡេងខ្លាំងថា "អេលី១ ល៉ាម៉ាសាបាច់ ថានី គឺស្រាយថា ឱព្រះអង្គ១នៃទូលបង្គំអើយ ហេតុអ្វីបានជាទ្រង់ចោលទូលបង្គំ"។ ហេតុអ្វីបានជាព្រះអម្ចាស់យេស៊ូវមានបន្ទូលពាក្យទាំងនេះ? ព្រះអង្គចង់មានបន្ទូលថា ព្រះជាម្ចាស់មិនអាចលប់លាងពិរុទ្ធភាពនៃអំពើបាប ខុសពីមធ្យោបាយដែលព្រះអម្ចាស់យេស៊ូវគ្រីស្ទ កំពុងតែទទួលនៅលើឈើឆ្កាងនេះទេ។ ដើម្បីលាងជម្រះអំពើបាបរបស់ជនដែលបានលន់តួអំពើបាបរបស់ខ្លួន ព្រះវរបិតាចាំបាច់ត្រូវបញ្ជូនព្រះអម្ចាស់យេស៊ូវគ្រីស្ទ អោយមកសុគតជំនួសអំពើបាបរបស់ជននោះ។ ការលន់តួអំពើបាប មិនអាចលុបលាងអំពើបាបបានទេ។ អំពើបាបរបស់អ្នកលន់តួ ត្រូវផ្ទេរទៅលើព្រះអម្ចាស់យេស៊ូវ។ ទ្រង់ត្រូវសុគតនៅលើឈើឆ្កាង ទើបអំពើបាបដែលបុគ្គលម្នាក់លន់តួ បានត្រូវលាងជម្រះស្អាត។ ឯការជម្រះនោះទៀតសោត គឺព្រះវរបិតាប្រើព្រះលោហិតរបស់ព្រះអម្ចាស់យេស៊ូវ ដើម្បីលាងអំពើបាបនោះ។ មែកហ៊ីសុបជាឈើឆ្កាងរបស់ព្រះអម្ចាស់យេស៊ូវ។ ឯឈាមដែលយកមែកហ៊ីសុបទៅជ្រលក់ដើម្បីប្រោះ ជាព្រះលោហិត

របស់ព្រះអម្ចាស់យេស៊ូវ ដែលបានប្រោសអោយមនុស្សលោកបានជ្រះស្អាតពីអំពើបាបរបស់ខ្លួន។

## សម្រែកទូលសូមការលាងសម្អាត
## និងសូមការរួមសម្ព័ន្ធវិញ្ញាណបរិសុទ្ធ

**សូមបាំងព្រះភក្រ្តទ្រង់ចេញពីអំពើបាបរបស់ទូលបង្គំ ហើយលុបគ្រប់ទាំងអំពើទុច្ចរិតរបស់ទូលបង្គំចេញ (ទំនុកដំកើង៥១:៩)។**

ព្រះបាទដាវីឌត្រូវការព្រះលោហិតរបស់ព្រះអម្ចាស់យេស៊ូវ ដើម្បីលាងសម្អាតអំពើបាបរបស់ទ្រង់។ អំពើបាបទាំងនោះ ទ្រង់បានប្រព្រឹត្តនៅចំពោះព្រះនេត្ររបស់ព្រះជាម្ចាស់។

**ឱព្រះអង្គអើយ សូមបង្កើតចិត្តបរិសុទ្ធនៅក្នុងទូលបង្គំ ហើយកែវិញ្ញាណក្នុងទូលបង្គំឱ្យត្រឹមត្រូវឡើង (ទំនុកដំកើង៥១:១០)។**

ពាក្យថា "បង្កើត" ត្រង់នេះ នៅក្នុងភាសាហេព្រើរឃើញមានប្រើដែរក្នុងគម្ពីរលោកុប្បត្តិ១:១។ ពាក្យ "បង្កើត" ក្នុងភាសាហេព្រើរហៅ "បារ៉ា" ប្រែថា

បង្កើតរូបរាងចេញពីរបស់ដែលគ្មានរូបរាង។ ព្រះបាទដាវីឌឥតមានចិត្តណាមួយល្អបណ្តាលអោយព្រះជាម្ចាស់យកទៅកែច្នៃហើយប្រើប្រាសទេ។ ព្រះបាទដាវីឌមិនមានចិត្តបរិសុទ្ធទាល់តែសោះ។ ស្តេចអង្គនេះបានទូលសូមអោយព្រះជាម្ចាស់បង្កើតចិត្តបរិសុទ្ធនៅក្នុងរូបលោក។

**សូមកុំចោលទូលបង្គំចេញពីចំពោះទ្រង់ ហើយកុំដកយកព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ចេញពីទូលបង្គំឡើយ (ទំនុកដំកើង៥១:១១)។**

ព្រះវិញ្ញាណនៃព្រះបានសណ្ឋិតលើព្រះបាទដាវីឌ ដើម្បីអោយស្តេចអង្គនេះមាននាទីជាបាវបម្រើរបស់ព្រះអង្គ។ បច្ចុប្បន្ន គ្រីស្ទបរិស័ទមិនចាំបាច់អធិស្ឋានសូមសេចក្តីនេះទៀតទេ ពីព្រោះព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះជាម្ចាស់មិនដែលចាកចោលពីជីវិតរបស់អ្នកជឿឡើយ។ បើយើងជាកូនព្រះ ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះជាម្ចាស់គង់ជាមួយយើងជានិច្ច។ ព្រះបាទដាវីឌ អធិស្ឋានទូលសូមដល់ព្រះជាម្ចាស់ អោយបន្តធ្វើការនៅក្នុងជីវិតរបស់លោក។ ដូច្នេះ បានជាស្តេចអង្គនេះ មានប្រសាសន៍បន្តទៅទៀតថា:

**សូមឱ្យទូលបង្គំមានចិត្តរីករាយ ចំពោះសេចក្តីសង្គ្រោះនៃទ្រង់ឡើងវិញ ហើយទប់ទល់ទូលបង្គំដោយព្រះវិញ្ញាណដ៏សទ្ធានៃទ្រង់ (ទំនុកដំកើង៥១:១២)។**

ព្រះបាទដាវីឌមិនបានបាត់បង់សេចក្តីសង្គ្រោះរបស់លោកទេ គឺលោកគ្រាន់តែបាត់បង់សេចក្តីអំណរ នៃសេចក្តីសង្គ្រោះរបស់លោកតែប៉ុណ្ណោះ។ ការដែលព្រះបាទដាវីឌចង់បានជាងគេបង្អស់គឺ:

**[១៣] នោះទូលបង្គំនឹងបង្រៀនពីអស់ទាំងផ្លូវនៃទ្រង់ ដល់មនុស្ស
ដែលប្រព្រឹត្តអំពើរំលង ដូច្នេះ នឹងមានមនុស្សបាបប្រែចិត្តត្រឡប់
មកឯទ្រង់ [១៥] ឱព្រះអម្ចាស់អើយ សូមបើកបបូរមាត់ទូលបង្គំ នោះ
មាត់ទូលបង្គំនឹងបានប្រកាសប្រាប់ ពីសេចក្តីសរសើររបស់ទ្រង់
(ទំនុកដំកើង៥១:១៣,១៥)។**

ព្រះបាទដាវីឌចង់សរសើរ និងចង់មានឯកសិទ្ធិដើម្បីថ្វាយពាក្យសរសើរដល់ព្រះជាម្ចាស់សារជាថ្មីម្តងទៀត។

**នោះទ្រង់នឹងសព្វព្រះហឫទ័យ ដោយដង្វាយនៃសេចក្តីសុចរិត**

**គឺជាដង្វាយដុតនឹងយញ្ញបូជាថ្វាយទាំងមូលផង ដូច្នេះគេនឹងថ្វាយគោឈ្មោលនៅលើអាសនានៃទ្រង់ (ទំនុកដំកើង៥១:១៩)។**

ព្រះបាទដាវីឌ មិនមែនគ្រាន់តែចង់សរសើរដល់ព្រះជាម្ចាស់តែប៉ុណ្ណោះទេ។ ស្តេចអង្គនេះចង់រស់នៅអោយបានគាប់ព្រះហឫទ័យដល់ព្រះជាម្ចាស់ថែមទៀតផង។

ទាក់ទងនឹងដំណើរហេតុការណ៍ខាងលើ ព្រះអម្ចាស់យេស៊ូវបានមានបន្ទូលទៅកាន់សិស្សរបស់ទ្រង់ ក្នុងគម្ពីរលូកាជំពូក៧ ពេលស្ត្រីម្នាក់យកទឹកភ្នែករបស់នាងលាងព្រះបាទទ្រង់ រួចហើយយកប្រេងក្រអូបមកអប់ដល់ព្រះអង្គ។ នៅពេលនោះមានគេបន្ទោសដល់នាង តែព្រះយេស៊ូវបានមានបន្ទូលនៅក្នុងគម្ពីរលូកា៧:៤៧ថា"...អំពើបាបដែលនាងមានច្រើនដល់ម្ល៉េះ ត្រូវបានអត់ទោសឱ្យហើយ ដ្បិតនាងមានសេចក្តីស្រឡាញ់ច្រើន ប៉ុន្តែ អ្នកណាដែលគេអត់ទោសឱ្យតិច នោះក៏ស្រឡាញ់តិច" (ខ្ញុំសម្រួលឃ្លានេះអោយងាយស្តាប់)។ នាងមានអំពើបាបជាច្រើន។ លុះព្រះជាម្ចាស់អត់ទោសអោយនាងហើយ នាងស្រឡាញ់ព្រះអង្គយ៉ាងខ្លាំង។ ករណីនេះ ត្រូវជាមួយនឹងព្រះបាទដាវីឌ។ ព្រះបាទដាវីឌ យល់ពីព្រះជាម្ចាស់បានអត់ទោសដល់អំពើបាបរបស់លោក។ លោកស្រឡាញ់ដល់ព្រះជាម្ចាស់កាន់តែខ្លាំង។

តើលោកអ្នកស្រឡាញ់ដល់ព្រះជាម្ចាស់កម្រិតប៉ុន្មានដែរសព្វថ្ងៃនេះ? ចុះអំពើបាបរបស់លោកអ្នកវិញ តើតិចឬច្រើន? ទោះតិចឬច្រើនក្តី តើលោកអ្នកបានលន់តួអំពើបាបរបស់លោកអ្នកចំពោះព្រះអង្គហើយឬនៅ? ថ្មីៗនេះ តើលោកអ្នកបានយំ

សោកដោយព្រោះលោកអ្នកបានប្រព្រឹត្តអំពើបាបណាមួយដែរឬទេ? លោកអ្នកបានទទួលបរាជ័យណាមួយក្នុងជីវិត? តើលោកអ្នកបានលន់តួអំពើបាបនោះហើយឬនៅ? អរគុណដល់ព្រះជាម្ចាស់ ពីព្រោះក្នុងព្រះអម្ចាស់យេស៊ូវ ទ្រង់មានការអត់ទោសបាប។ ប៉ុន្តែ ខាងយើង យើងចាំបាច់ត្រូវលន់តួអំពើបាបរបស់យើងចំពោះទ្រង់ ដើម្បីទទួលការលាងជម្រះអំពើបាបរបស់យើង។ យើងអាចទទួលការលាងជម្រះអំពើបាបបានដោយសារព្រះជាម្ចាស់ផ្តួចផ្តើមគំនិត អោយយើងបានជ្រះអំពើបាបរបស់យើងតាមរយៈការសុគត និងការរស់ឡើងវិញ នៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

យើងស្លេះការសិក្សាគម្ពីរទំនុកដំកើងត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"